## អ្នកជំនាញ អ.ស.ប ព្រមានថា ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន របស់ប្រទេសកម្ពុជា បង្កគ្រោះថ្នាក់ដល់សិទ្ធិមនុស្ស

ទីក្រុងហ្សឺណែវ (១៧ មេសា ២០២០) – ក្រុមអ្នកជំនាញ អ.ស.ប បានមានប្រសាសន៍នៅថ្ងៃនេះថា ច្បាប់ថ្មី ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន របស់រដ្ឋាភិបាលកម្ពុជា ក្នុងការឆ្លើយតបទៅនឹងហានិភ័យដោយការរាតត្បាតនៃជំងឺកូវីដ-១៩ រំលោភសិទ្ធិឯកជន រឹតត្បិតការបញ្ចេញមតិដោយសេរី និងដាក់ជាបទព្រហ្មទណ្ឌចំពោះការជួបប្រជុំដោយសន្តិវិធី។

លោកស្រី រ៉ូណា ស្មីត អ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានមានប្រសាសន៍ថា" វិធានការនានាដែលដាក់ចេញក្នុងស្ថានភាពមានអាសន្ន ត្រូវតែជាការចាំបាច់ និងសមាមាត្រទៅនឹងវិបត្តិ នានាដែលត្រូវស្វែងរកដំណោះស្រាយ" ។ "ពាក្យក្នុងន័យទូលាយ អំពីការការពារសន្តិសុខជាតិ និង សណ្តាប់ធ្នាប់សាធារណៈ ដែលទំនងជាមានគោលបំណងដោះស្រាយបញ្ហាជំងឺកូវីដ-១៩ អាចត្រូវបានយកមកប្រើជាសក្តានុពល ដើម្បីរំលោភលើសិទ្ធិឯកជន និងរឹតត្បិតដោយមិនចាំបាច់នូវសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិសេរីភាពខាងសមាគម និងសិទ្ធិជួបប្រជុំដោយសន្តិវិធី" ។

ច្បាប់នេះ ផ្តល់អំណាចទូលំទូលាយ ដល់រដ្ឋាភិបាលក្នុងរយៈពេល ៣ ខែដំបូង រួមមានការរឹតត្បិត និងការហាមឃាត់លើការចែកចាយព័ត៌មាន និងវិធានការសម្រាប់ " ការតាមឃ្លាំមើល និងតាមដានតាមគ្រប់មធ្យោបាយ" ។ ច្បាប់នេះ ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី១០ ខែមេសា ហើយត្រូវបានរំពឹងថា ព្រឹទ្ធសភានឹងអនុម័តយល់ព្រម នៅថ្ងៃទី១៧ ខែមេសា។ អ្នករាយការណ៍ពិសេសបានមានប្រសាសន៍ថា បទល្មើស ដូចជា "ការរារាំង" ឬ "ការបង្កឧបសគ្គ" ដល់ប្រតិបត្តិការរបស់រដ្ឋាភិបាល បានបើកផ្លូវឲ្យមានការបកស្រាយ និងការដាក់ពន្ធនាគាររហូតដល់ ១០ ឆ្នាំ" និងពិន័យជាប្រាក់យ៉ាងច្រើន ដែលមិនសមាមាត្រ។

" ការដាក់ទោសទណ្ឌ និងការផាកពិន័យ គួរតែស្របទៅនឹងស្ថានទម្ងន់ទោសដែលបានប្រព្រឹត្ត ដោយពិចារណាទៅលើស្ថានភាពសេដ្ឋកិច្ចរបស់បុគ្គលម្នាក់ៗ។ បញ្ហានេះ ពាក់ព័ន្ធជាពិសេស សម្រាប់អ្នកគ្មានការងារធ្វើ និងឬ មិនអាចរកប្រាក់ចំណូលបានដោយសារតែវិធានការបន្ទាន់នេះ។" នេះបើតាមប្រសាសន៍របស់លោកស្រី ស្មីត។

អ្នកជំនាញបានមានប្រសាសន៍ថា ច្បាប់គួរតែផ្តោតលើការដោះស្រាយពីតម្រូវការសុខភាពសាធារណៈ តែ ក៏ត្រូវការពារសេរីភាពជាមូលដ្ឋានផងដែរ។ " អាជ្ញាធរកម្ពុជា គួរតែចាត់វិធានការយ៉ាងសកម្ម ដើម្បីធានាថា មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នា ក្នុងការទទួលបានសេវាសុខភាពសមរម្យ និងអនុម័តវិធានការពិសេសសម្រាប់បុគ្គលនិងក្រុមនានាដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ រួមទាំងអ្នកដែលមានជម្ងឺរ៉ាំរ៉ៃ ជនពិការ មនុស្សចាស់ជរា ជនជាប់ឃុំ ប្រជាជនក្រីក្រនៅតាមជនបទ ជនជាតិដើមភាគតិច និងជាតិពន្ធុភាគតិចជាដើម។ "

លោកស្រី ស្មីត បានមានប្រសាសន៍ថា ទណ្ឌកម្ម និងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់ថ្មីនេះចំពោះនីតិបុគ្គល ក៏អាចរួមបញ្ចូលផងដែរ នូវសង្គមស៊ីវិល និងអង្គការសិទ្ធិមនុស្សទាំងឡាយ ដែលប្រតិបត្តិការនៅក្នុងបរិយាកាសមួយដែលមានការរឹតត្បិតខ្លាំងរួចទៅហើយ។ លោកស្រី ស្មីត បានមានប្រសាសន៍ថា “ស្ថានភាពអាសន្ន គួរតែត្រូវបានណែនាំដោយគោលការណ៍សិទ្ធិមនុស្ស ហើយទោះជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ មិនគួរយកធ្វើជាលេស ឬជាការដោះសារណាមួយ ចំពោះការបង្ក្រាប ក្រុមអ្នកមានមតិប្រឆាំង ឬផលប៉ះពាល់មិនសមាមាត្រា និងអវិជ្ជមានដល់ក្រុមណាមួយផ្សេងទៀតឡើយ។”

អ្នករាយការណ៍ពិសេសបានមានប្រសាសន៍ថា “ នៅពេលដែលប្រទេសកម្ពុជា ចូលរួមជាមួយបណ្ដារដ្ឋផ្សេងៗកាន់តែច្រើនឡើងៗ ដែលបានប្រកាសពីវិធានការពិសេស ដើម្បីដោះស្រាយការគំរាមកំហែងដល់សុខភាពសាធារណៈដែលបង្កឡើងដោយការរាតត្បាតនៃជំងឺកូវីដ -១៩ វាជាការចាំបាច់ណាស់ដែលថា សិទ្ធិមនុស្សគឺជាចំណុចស្នូលនៃការឆ្លើយតបរបស់ខ្លួន។”

អ្នករាយការណ៍ពិសេស បានទាក់ទងជាមួយរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងខាងលើនេះ។

សេចក្តីថ្លែងការណ៍របស់លោកស្រី រ៉ូណា ស្មីត ត្រូវបានឯកភាពយល់ព្រមដោយលោក Dainius Pras អ្នករាយការណ៍ពិសេស ស្តីពីសិទ្ធិសុខភាពរាងកាយ និងសុខភាពផ្លូវចិត្ត។ លោកស្រី Fionnuala D. NíAoláin អ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ទន្ទឹមនឹងប្រឆាំងនឹងអំពើភេរវកម្ម។ លោកស្រី Agnès Callamard អ្នករាយការណ៍ពិសេសស្តីពីការសម្លាប់ភ្លាមៗ ឬតាមអំពើចិត្តក្រៅប្រព័ន្ធតុលាការ និងក្រុមការងារស្តីពីការឃុំខ្លួនដោយបំពាន លោក Jose Jose Antonio Guevara Bermúdez (ម៉ិកស៊ិក ប្រធានអ្នករាយការណ៍) លោកស្រី Elina Steinerte (ឡេតូនី អនុប្រធានផ្នែកតាមដាន) លោកស្រី Leigh Toomey (អូស្ត្រាលី អនុប្រធានផ្នែកទំនាក់ទំនង) លោក Sètondji Roland Adjovi (បេណាំង) និងលោក Seong-Phil Hong (សាធារណរដ្ឋកូរ៉េ)

**ចប់**

***សាស្ត្រាចារ្យ រ៉ូណា ស្មីត*** *(ចក្រភពអង់គ្លេស) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០១៥។*

*អ្នករាយការណ៍ពិសេស ពួកគាត់គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប)គឺជាឈ្មោះទូទៅមួយនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ។ អ្នកកាន់អាណត្តិនីតិវិធីពិសេស គឺជាអ្នកជំនាញ ឯករាជ្យ ដែលក្រុមប្រឹក្សាសិទ្ធិមនុស្សបានតែងតាំងឡើង ដើម្បីធ្វើការងារពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសមួយជាក់លាក់ ឬបញ្ហាសិទ្ធិមនុស្សតាមវិស័យ នីមួយៗ នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយធ្វើការ*

*ឯករាជ្យពីរដ្ឋាភិបាល និង អ.ស.ប។ ពួកគាត់បំរើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ខ្លួន ហើយមិនទទួលប្រាក់បៀវត្សរ៍លើការងារនេះឡើយ។*

*សូមស្វែងរកមើលរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីប្រទេសកម្ពុជា និងទំព័រហ្វេសប៊ុករបស់អ្នករាយការណ៍ពិសេស៖* https://www.facebook.com/SpecialRapporteurCambodia/?modal=admin_todo_tour

*សិទ្ធិមនុស្ស អ.ស.ប ទំព័រប្រទេស៖ កម្ពុជា*

*សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មាន**ផ្សេងៗ សូមទាក់ទង៖ អ្នកស្រី អ៊ីស្ទឺរ ឡាំ (Esther Lam) តាមរយៈអ៊ីម៉ែល៖ (elam@ohchr.org) លោក ម៉ាស់មូដ ហ្គារហ្គា (Mahmoud Garga) តាមរយៈទូរស័ព្ទលេខ៖ (+៨៥៥ (០)១២ ៧៩០ ១៧៨ ឬអ៊ីម៉ែល៖ mgarga@ohchr.org)*

*សម្រាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទង៖*
*លោក សាប៊ៀរ សេឡាយ៉ា (Xabier Celaya) តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩១៧ ៩៤៤៥ ឬ អ៊ីម៉ែល xcelaya@ohchr.org)*

*តាមមើលព័ត៌មានពាក់ព័ន្ធនឹងអ្នកជំនាញឯករាជ្យដទៃទៀតរបស់ អ.ស.ប នៅលើធ្វីតធឺរ* @UN_SPExperts

*តើអ្នកខ្វល់អំពីពិភពលោកដែលយើងរស់នៅ ឬទេ?*
***ដូច្នេះ ក្រោកឈរដើម្បីសិទ្ធិរបស់នរណាម្នាក់នៅថ្ងៃនេះ***
*#ក្រោកឈរដើម្បីសិទ្ធិមនុស្ស*
*និងចូលទៅកាន់គេហទំព័រ* http://www.standup4humanrights.org